ស្ថានទូតអូស្ត្រាលី ភ្នំពេញ

**សេចក្តីប្រកាសព័ត៌មាន**

ថ្ងៃទី ៤ ខែ មេសា ឆ្នាំ២០១៩

# ការប្រកាសបើកសិក្ខាសាលាថ្នាក់តំបន់ស្តីពី ស្ត្រីនិងភាពជាអ្នកដឹកនាំ

នៅរាត្រីទី ៤ ខែ មេសា ឆ្នាំ២០១៩នេះ **លោកជំទាវ អេនជេលឡា ខកខឺរ៉េន** ឯកអគ្គរាជទូតអូស្ត្រាលីប្រចាំកម្ពុជា នឹងបើកជាផ្លូវការនូវសិក្ខាសាលាថ្នាក់តំបន់ស្តីពី ស្ត្រីនិងភាពជាអ្នកដឹកនាំ។

សិក្ខាសាលាថ្នាក់តំបន់ស្តីពី ស្ត្រី និងភាពជាអ្នកដឹកនាំ រៀបចំឡើងនៅទីក្រុងភ្នំពេញ។ សិក្ខាសាលានេះ គឺជាជំហានដំបូង ឈានទៅបង្កើតវេទិកាថ្នាក់តំបន់មួយ ដែលផ្សាភ្ជាប់ស្ត្រី មកពីបណ្តាប្រទេសនានា ក្នុងសមាគមន៍អាស៊ាន តាមរយៈកម្មវិធីអាហារូបករណ៍អូស្ត្រាលី។

លោកជំទាវឯកអគ្គរាជទូត មានប្រសាសន៍ថា៖ "នៅទូទាំងតំបន់ឥណ្ឌូប៉ាស៊ីហ្វិកយើង ស្ត្រីកំពុងដើរតួនាទីយ៉ាងសំខាន់ នៅក្នុងជួររដ្ឋាភិបាល វិស័យឯកជន ការអភិវឌ្ឍន៍ និង សង្គមស៊ីវិល"។

លោកជំទាវបន្តទៀតថា៖ "រដ្ឋាភិបាលអូស្ត្រាលីមានការប្តេជ្ញាចិត្តខ្ពស់ក្នុងការគាំទ្រស្ត្រីទាំងនោះ ផ្តល់សិទ្ធិអំណាចដល់ស្ត្រី ព្រមទាំងជំរុញស្ត្រីអោយមានភាពជាអ្នកដឹកនាំ និងចូលរួមយ៉ាងសកម្មក្នុងអាជីពការងារ"។

អតីតនិស្សិតស្ត្រីដែលបានទទួលអាហារូបករណ៍អូស្ត្រាលី មកពីប្រទេសកម្ពុជា ឥណ្ឌូណេស៊ី ឡាវ ភូមា ហ្វីលីពីន និង វៀតណាម ចំនួនជាង ៧០រូប នឹងមកចូលរួមសិក្ខាសាលារយៈពេលបីថ្ងៃនេះ ចាប់ពីថ្ងៃទី ៤ដល់ទី ៦ ខែមេសា។

លោកជំទាវ មានប្រសាសន៍បន្តទៀតថា៖ " ខ្ញុំមានក្តីសោមនស្សរីករាយណាស់  ដែលបានឃើញស្ត្រីដែលមានការអប់រំខ្ពស់ និងបទពិសោធន៍ច្រើន ឆ្លៀតពេលវេលាដ៏មមាញឹករបស់ពួកគេ មកចែករំលែកបទពិសោធន៍ និងសិក្សាពីគ្នាទៅវិញទៅមកនៅក្នុងសិក្ខាសាលានេះ"។

សិក្ខាសាលាថ្នាក់តំបន់ ស្តីពីស្ត្រី និងភាពជាអ្នកដឹកនាំនេះ បានទទួលការឧបត្ថម្ភថវិកាទាំងស្រុងពីរដ្ឋាភិបាលអូស្ត្រាលី។

ទំនាក់ទំនងព័ត៌មាន៖ Australian.Embassy.Cambodia@dfat.gov.au